**TKI0761**

# សម្ភាសន៍ជាមួយឈ្មោះ សាច់ ដែន ភេទស្រី អាយុ៥៣ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ សេដ្ឋកិច្ចឃុំកំពែង

## សព្វថ្ងៃនៅភូមិសំរោងខាងកើត ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ស សេងគា

០០:៥៣:៣៨

២៨ទំព័រ

សេងគា ៖ មីង ខ្ញុំហ្នឹងឈ្មោះ ស សេងគា ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលស្វែងរកឯកសារប្រវត្តិសាស្ត្រ គឺការចងចាំប្រវត្តិសាស្ត្រនឹង និងស្វែងរកយុត្តិធម៌។ តែយុត្តិធម៌ខាងតុលាការទេ ខាងខ្ញុំខាងជួយរំលឹកពីការចងចាំពីសម័យនឹង។ ដើម្បីឲ្យក្មេងៗបានដឹង ហើយដើម្បីទប់ស្កាត់ក្មេងៗកុំឲ្យធ្វើអំពើចឹងទៀត។ ហើយមកដូះមីងនេះ គឺចង់បានបទសម្ភាសន៍របស់មីង ហើយយកមកសាច់រឿងមីងអាចសរសេរជាអត្ថបទ ចុះក្នុងទស្សនាវដ្ដី ចុះក្នុងកាសែតអីចឹង ហើយនឹងស្រាវជ្រាវជាឯកសារផ្សេងៗទៀត។ ចឹងបើសិនជាខ្ញុំយកប្រើចឹង មីងអត់ថាអី មីង?

ដែនៈ ចុះមានទៅ ស្រេចប្អូនឯង។

សេងគា ៖ ចឹងកាលណាយើងសុំសម្ភាសន៍ចឹង យើងសុំការអនុញ្ញាតិពីមីង?

ដែនៈ ចា៎!

សេងគា ៖ ព្រោះអីខ្លាចមីងបារម្ភអី ប្រាប់មុនឲ្យហើយ ខាងខ្ញុំយកទៅដើម្បីធ្វើចឹង។

ដែនៈ ខ្ញុំគ្មានបារម្ភស្អីទេ។

សេងគា ៖ ចឹងខ្ញុំក៏ចង់ដឹងពីរឿងរ៉ាវខ្លះៗរបស់មីងៗ មានស្រុកកំណើតនៅណា?

ដែនៈ នៅនឹង។

សេងគា ៖ ឃុំអីដែរ?

ដែនៈ ភូមិសំរោងខាងកើត ឃុំគោរព្រេច ស្រុកគិរីវង់ ខេត្តតាកែវ។

សេងគា ៖ ចឹងមីងឈ្មោះ?

ដែនៈ សាច់ ដែន។

សេងគា ៖ មីងមានអាយុប៉ុន្មានហើយ?

ជែន៖ ៥៣ ។

សេងគា ៖ មីងប្រកបរបរធ្វើអីដែរ?

ជែន៖ ធ្វើស្រែ ។

សេងគា ៖ មានបងប្អូនប៉ុន្មាននាក់ដែរ?

ជែន៖ បងប្អូនខ្ញុំ៩នាក់ ។

សេងគា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ជែន៖ ប្រុស៣ ប៉ុនស្លាប់មួយហើយ នៅតែ២ ។

សេងគា ៖ ប្រុស៣?

ជែន៖ ប្រុស៣ ស្រី៦ ។

សេងគា ៖ មីងជាកូនទីប៉ុន្មាន?

ជែន៖ ខ្ញុំកូនទី៣ ។

សេងគា ៖ ថ្ងៃនេះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០ ។ ចឹងមីងបច្ចុប្បន្នរស់នៅភូមិ?

ជែន៖ ចា៎! សំរោងកើត ។

សេងគា ៖ ភូមិសំរោងខាងកើត ឃុំគោព្រេច ស្រុកគិរីវង់ ខេត្តតាកែវ ។ មីងឥឡូវមានកូនប៉ុន្មាននាក់ហើយ?

ជែន៖ កូន៧ ។

សេងគា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ជែន៖ ប្រុស៣ ស្រី៤ តែប្រុសការហើយ១ហើយ នៅស្រីទាំងអស់ ។

សេងគា ៖ មានកូនកើតទាន់សម័យខ្មែរក្រហមទេ?

ជែន៖ គ្មានទេ ។

សេងគា ៖ ទាល់តែខ្មែរក្រហមហើយបានមាន?

ជែន៖ ចា៎! ខ្មែរក្រហមខ្ញុំប្តេជ្ញាខ្មែរក្រហម ដល់ស្រុកយើងចឹងបានមានកូន ។ ប៉ុនប្តេជ្ញាហើយបាន ប៉ុន្មាន ។

សេងគា ៖ ប្តីរបស់មីងឈ្មោះអីដែរ?

ជែន៖ ឥឡូវដាក់ឈ្មោះឥឡូវ ក៏ឈ្មោះមុន ។

សេងគា ៖ ដាក់ឥឡូវក៏បាន ។

ជែន៖ ឈ្មោះគេ ឃួន សុខុន ។

សេង៉គា ៖ គាត់ធ្វើការអីគេ?

ដែន៖ គាត់ធ្វើប៉ូលីស ។

សេង៉គា ៖ ស្រុកកំណើតគាត់នៅណាដែរ?

ដែន៖ នៅភ្នំវន្ទះ ។

សេង៉គា ៖ ឃុំអីគេ?

ដែន៖ ឃុំអន្ទប្រាសាទ គិរីវង់ ខេត្តតាកែវដូចគ្នា ។

សេង៉គា ៖ ចឹងមីងមានកូនពីឆ្នាំ៨០ជាង ឬ៨០?

ដែន៖ មកស្រុកចឹង ដឹងឆ្នាំប៉ុន្មាន ។

សេង៉គា ៖ ដល់បែកអាពតហើយបានប៉ុន្មានឆ្នាំ?

ដែន៖ ចុះមកពីលើឆ្នាំប៉ុន្មាន ។

សេង៉គា ៖ មីងកាលនឹងមានបានចូលរៀនអីទេ កាលដែលមុនពីអាពត?

ដែន៖ ពីសង្គមចាស់មក?

សេង៉គា ៖ បាទ! ពីសង្គមចាស់មក?

ដែន៖ រៀន ។

សេង៉គា ៖ មីងចូលរៀនពីអាយុប៉ុន្មាន?

ដែន៖ មិនដឹង អត់ចាំ ។

សេង៉គា ៖ ក្មេច?

ដែន៖ អឺ! ប៉ុនរៀនដល់ថ្នាក់ទី៧ ។

សេង៉គា ៖ ទី៧ ឥឡូវស្មើនឹងថ្នាក់ទីប៉ុន្មាន?

ដែន៖ អត់ដឹង ។

សេង៉គា ៖ ទី៧ គេរាប់ពីទី១២ ១១?

ដែន៖ យើងចូលទី៦ យើងប្រឡងឌីប្លូមនៅគិរី(គិរីវង់) ។

សេង៉គា ៖ ចឹងមីងបានថ្នាក់ទី៧?

ដែន៖ ទី៧ពីដើម ។

សេង៉គា ៖ មានកូន៧នាក់ ស្រីប៉ុន្មាន?

ដែន៖ ស្រី៤ ប្រុស៣ ។

សេង៉គា ៖ ប្ដីឈ្មោះអីខុន?

ដែនៈ ឃួន ខុន ។

សេងគា ៖ រៀនដល់ថ្នាក់ទី៧ទៅ បានមានរដ្ឋប្រហារ?

ដែនៈ ចា៎! រដ្ឋប្រហារ ។

សេងគា ៖ កាលរដ្ឋប្រហារ មីងរៀននៅសាលាណា?

ដែនៈ នៅព្រៃដើង ។

សេងគា ៖ នៅសាលាអីវិញ?

ដែនៈ សុខអានព្រៃដើង ។

សេងគា ៖ ចឹងមីងរៀននៅសាលានឹង រៀនទៅមានរដ្ឋប្រហារមកមីងរត់ទៅណា?

ដែនៈ រត់ទៅលើ ។

សេងគា ៖ ទៅណាទៅលើ?

ដែនៈ ទៅដល់ ទៅដឹងទៅឆ្ងាយៗ ហើយយើងបានចុះមកវិញ បានចងក្រងធ្វើកងនារីកងអីចឹង ។

សេងគា ៖ ចឹងរត់ទៅស្រុកលើៗ ខេត្តអី ខេត្តតាកែវ ខេត្តកំពត?

ដែនៈ ខេត្តកំពត ។

សេងគា ៖ នៅភូមិអី ស្រុកអី?

ដែនៈ មិនទៀងដើរគ្រប់កន្លែង ។

សេងគា ៖ ដល់ពេលរត់ទៅនឹងរត់ទាំងគ្រួសារ?

ដែនៈ រត់ទៅទាំងគ្រួសារ ទាំងម៉ែទាំងឪ ។

សេងគា ៖ មានគ្នាប្រហែលប៉ុន្មាននាក់?

ដែនៈ ទៅច្រើនណាស់ ម៉្មាស្រុកទៅទាំងអស់ទៅនៅកក់គ្នាដូច ។

សេងគា ៖ ចឹងពេលរត់ទៅនឹង ជិះអីទៅបរទេះគោទៅឬក៏?

ដែនៈ បរទេះគោទៅ ។

សេងគា ៖ ទៅទាំងភូមិនឹងទាំងអស់?

ដែនៈ ទៅអស់រលីង ។

សេងគា ៖ ម៉េចបានរត់ចឹង ពេលរដ្ឋប្រហារធ្លាក់គ្រាប់នឹងច្រើន ឬក៏ម៉េច?

ដែនៈ គ្រាប់ភ្លោងមកពីយួន ។

សេងគា ៖ ហើយមានយន្តហោះធ្លាក់ពីលើទេ?

ផែនៈ	យន្តហោះអត់មានទម្លាក់ទេ ស្រុកយើងនឹង ៗ មានតែគ្រាប់ពីនោះមក កាប៉ាល់ហោះគ្មានទម្លាក់ទេ ក្រោយមកទៀត ៗ

សេងគា ៖	នៅពេលទៅដល់កំពតនឹង ជិះទៅប៉ុន្មានថ្ងៃបានទៅដល់នឹង?

ផែនៈ	ទៅដេកនេះដេកនោះរហូតមិនទៀង ៗ

សេងគា ៖	ប្រហែលជាប៉ុន្មានទៅដល់កំពតនឹង ដើរពីនេះទៅ?

ផែនៈ	២ថ្ងៃ ៗ

សេងគា ៖	ចឹងនៅពេលដែលមីងរត់ទៅដល់នឹងហើយ ទៅដល់នឹងនៅកន្លែងណាដែរ កំពតនឹង?

ផែនៈ	អត់ស៊ីក្រោមដើមឈើ ក្រោមដើមព្រៃចឹង មិននៅផ្ទះគេទេ នៅក្រោមដើមឈើ ៗ

សេងគា ៖	នៅណាទៀត ដើមឈើ បន្ទាប់មកនៅបានរយៈពេលប៉ុន្មាន បានរត់មកវិញ? ឆ្នាំ៧០ ប៉ុន្មានបានមកនេះវិញ? និយាយទៅពី៧០?

អ្នកជិតខាងប្រុសៈ កាលគេបាញ់មកប្រាវៗ យើងរត់ទៅរត់មករហូត ៗ

អ្នកជិតខាងស្រីៈ ដល់ពេលគេផ្អាកលែងមានចឹងទៅ យើងចុះមកមើលស្រូវមើលអង្ករមើលផ្ទះមើលសម្បែងចឹងទៅ ដល់ពេលថាមកទៀតហើយទៅទៀត កាលនឹងច្រើនសារណាស់ ៗ

សេងគា ៖	ចឹងរត់ចឹងរហូត?

ផែនៈ	អឺ!

សេងគា ៖	ដល់ឆ្នាំប៉ុន្មាន បានខាងនេះជាប់ទៅធ្វើកងវិញ ៧០ប៉ុន្មាន?

អ្នកជិតខាងប្រុសៈ ៧៧ ៗ

សេងគា ៖	៧៧បានមកវិញ ឬក៏៧៥ទេ?

អ្នកជិតខាងប្រុសៈ ៧៧ហើយ គេរៀបចំអាពតត្រឹមត្រូវនឹង ៗ

សេងគា ៖	ចឹងនៅនឹងរហូតដល់៧៧បានមកវិញ?

ផែនៈ	ដល់គេរៀបចំ ៗ

សេងគា ៖	ដល់ហូបបាយរួម ៧៦ ៧៧?

អ្នកជិតខាងប្រុសៈ ៧៦យើងរួមក្រុម កាលយើងអត់ទាន់នេះ អត់ទាន់រួមក្រុមទេ នៅរគាតរគាយបាយផ្ទះតិចតួចទេ ៗ ដល់ពេលគេរួមឆ្នាំងខ្វះតែមួយនឹង អានឹង៧៧ ៗ

សេងគា ៖	ចឹងពេលដែលមកឆ្នាំ៧៦នឹង មីងចូលមកនឹង មីងបានចូលធ្វើការជាមួយមីងភីនឹងហើយ?

ផែនៈ	ចាំ! ភីនឹង ៗ

សេងគា ៖	កាលនឹងគេឲ្យមីងធ្វើអី?

ដែនៈ ខ្ញុំកងនារី ។

សេងគា ៈ កងនារី មីងភីជាប្រធាន?

ដែនៈ ចាំ!

សេងគា ៈ ចុះមីងភីអ្នកចាត់ចែងឲ្យធ្វើ?

ដែនៈ ចាំ!

សេងគា ៈ ចុះបងប្អូនស្រីៗរបស់មីងទៀត ឲ្យធ្វើដែរ ឬ?

ដែនៈ កូនស្រីនឹង ។

សេងគា ៈ មានបងប្អូនស្រីមួយនោះ?

ដែនៈ នៅកងខុសគ្នា តូចៗ ។

សេងគា ៈ នៅកងខុសគ្នា?

ដែនៈ ចាំ!មួយកងកុមារចឹងទៅ ។

សេងគា ៈ តែមីងភីអ្នកកាន់កាប់ដែរ ឬក៏អ្នកផ្សេងទេ?

ដែនៈ ហេ៎! កុមារដោយខ្លួន ភីនឹងគាត់ខាងនារីពេញៗម៉ង ។

សេងគា ៈ ខាងយុវនារី ហើយខាងនារីនឹងហើយ?

ដែនៈ ចាំ! ហើយកុមារដោយខ្លួនទៅ ប៉ុនកុមារ ។

សេងគា ៈ មីងមានដឹងទេ ថានៅកងនឹងមានគ្នាប៉ុន្មាននាក់ដែរ ដែលកងមីងដេកជាមួយមីងភីនឹង?

ដែនៈ ច្រើនរាប់ពាន់ ២០០០នាក់ ។

សេងគា ៈ មីភីក្តាប់ទាំងអស់ ឬក៏ម៉េច?

ដែនៈ ភី ។

សេងគា ៈ មីងភីជាមនុស្សម៉េចដែរ?

ដែនៈ អត់មានម៉េចទេ ។ មិនកាចប៉ុន្មានទេ គេចាត់ចែងលើគាត់ ប៉ុនគាត់មិនប្រើអំពើហិង្សាពេក អត់មានសូវដែលធម្មតា ។ អ្នកស្រុកភូមិនិយាយរួម ។ ធ្វើទៅអាខ្លះកាចណាស់ មិនដឹងបងដឹងប្អូនទេ បើគាត់ធម្មតាដែរ ។

អ្នកជិតខាងស្រី ៈ អានឹងនេះគាត់មកក្តោបក្តាប់កុមារម្តង ប៉ុនគាត់ធ្វើធំជាងគេ ដល់ពេលមក ។

សេងគា ៈ ហើយក្រោមបងភីមានពីណាគេទៀត?

ដែនៈ ក្រោយភីមក ....(ស្តាប់មិនបាន)មិនដឹងទេ គ្មានទេ គ្មានអ្នកណាទៀតទេ ។ ប៉ុងនឹង ក្រោមភី ។

សេងគា ៖ ភីហើយ ប៉ុនទៀត?

ដែនៈ ចា៎! ប៉ុន ។

អ្នកជិតខាងស្រី ៖ ឥឡូវប៉ុននៅណា?

អ្នកជិតខាងប្រុស ៖ នៅស្រុកលើ ស្រុកមោង(មោងឫស្សី) ទៅជាមួយអាវុធ ។

សេងគា ៖ ឥឡូវគាត់នៅណា?

ដែនៈ អត់ដឹងខេត្តណា ។

សេងគា ៖ អត់ដឹងថាគាត់ស្លាប់ ឬរស់?

ដែនៈ មិនដឹងទេ ប្អូនឆ្ងាយ ដឹងទៅបាត់ណាទៅហើយ ។

សេងគា ៖ ហើយក្រោយពីប៉ុនមានអ្នកណាគេទៀត?

ដែនៈ មើលនេះ បងប៉ុននឹង បងសៀមនឹង ៣នាក់គ្នាគាត់ បងសៀមនៅត្រាំកក់ ។ បងសៀម ភី គេឲ្យនៅជាមួយកងសៀម ដល់នេះទៅកងពិសេស គេកងថ្មើរជើង ។

សេងគា ៖ ចឹងរាល់ថ្ងៃគាត់នៅរស់?

ដែនៈ បងសៀមនឹង គាត់ស្លាប់ហើយ រត់ឡើងទៅលើ គេស្លាប់ កប់ គេហែកស៊ី...(ស្តាប់មិនបាន) ប្រពន្ធគាវ៉ន នៅក្បាលដីរនេះ មិនគាត់ស្លាប់ទៅយកទៅកប់ចោល គេទៅកាយស៊ី អត់បាយអត់ទឹកជំនាន់នឹង ។ ពូពូវ៉ននិយាយមិនដឹង ពូៗគេនិយាយមិនដឹងមានអត់ទេ ។ មិនទេ គាត់ស្លាប់កូនង៉ែត ។

សេងគា ៖ មីងភី នឹងគាត់ស្លូតចំពោះតែអ្នកភូមិជាមួយគ្នា អ្នកភូមិផ្សេងអត់ស្លូតចឹងណា ឬក៏យ៉ាងម៉េច?

ដែនៈ មិនដឹងទេម៉េចប្អូន ចំពោះអ្នកស្រុកអ្នកភូមិអត់អីទេ ។

សេងគា ៖ មីងមានដែលឃើញគាត់ធ្វើបាបគេ?

ដែនៈ អត់ដែលឃើញទេ ។

សេងគា ៖ ហើយដូចថាមានអ្នកធ្វើខុស ខុសសីលធម៌ គាត់ដែលយកធ្វើអី?

ដែនៈ គាត់គ្រាន់សម្តីអាក្រក់តិច ប៉ុនធ្វើបាបអត់ទេ គាត់ស្តីសម្តីអាក្រក់តិចទៅណា ត្រង់យកគេទៅធ្វើបាប អត់ដែលឃើញទេ មិនកុហក មិនលាក់មិនលៀមអីទេ ។ តែដល់ពេលគាត់ខឹង គាត់ប្រើសម្តីមកលើយើង ខ្វះចឹងៗដែលទៅ ។

សេងគា ៖ ចឹងមីងនៅក្នុងកងរយៈពេលមីងនៅជាមួយកងមីងភី មានដែលឃើញអ្នកណាគេធ្វើបាបមនុស្សស្រី ចាប់រំលោភចាប់អីមានទេ?

ដែនៈ អត់មានទេ ។

សេងគា ៈ ខុសសីលធម៌ គេយកធ្វើអី មានទេ?

ដែនៈ អត់មានឃើញ តែហ៊ានម៉េចហ៊ាន ដល់ហើយស្មោះត្រង់គ្រប់តែគ្នាចឹងទៅ មិនហ៊ាន ។

សេងគា ៈ ហើយកាលនឹងនៅកងគេឲ្យធ្វើអីខ្លះ?

ដែនៈ ឲ្យវែកប្រឡាយ ។

សេងគា ៈ អីទៀត?

ដែនៈ ស្ទូងដកគ្រប់តែមុខនឹង តែប៉ុននឹង ជីកប្រឡាយ លើកភ្លឺស្រែ កាត់ស្មៅ ស្ទូងនឹងស្ទូងយប់ ។

សេងគា ៈ ហើយគេឲ្យធ្វើចឹង ធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានកាលនឹង?

ដែនៈ ពីម៉ោង៧ចឹងរហូតដល់ម៉ោង១១ ហូបបាយម៉ាភ្លែតចុះទៀត ធ្វើទាំងយប់ទល់ម៉ោង៥-៦យប់ ។

សេងគា ៈ ហើយយប់ធ្វើទៀតទៅ?

ដែនៈ យប់អត់មានធ្វើទៀតទេ កាលណាថ្ងៃក្រោកថ្ងៃណាខែណាគេធ្វើៗម៉ង ប៉ុនអីអត់ដែលធ្វើទេពេលយប់ ។

សេងគា ៈ ហើយ នៅក្នុងកងនឹង គេឲ្យហូបបាយធម្មតាទេ?

ដែនៈ ហូបបបរៗអត់ឆ្អែតទេ ។

សេងគា ៈ មីងខ្លះថាកន្លែងខ្លះគេថាពិបាកណាស់ ម៉ាថ្ងៃគាត់បានអង្ករម៉ាកំប៉ុង២នាក់ ។

អ្នកជិតខាងស្រីៈ អានឹងគេអ្នកពេញសិទ្ធិ តែពួកយើងផ្ញើ ពួកយើងត្រៀមមិនបានទេ ។

សេងគា ៈ មីងកាលនឹងជាប្រជាជបផ្ញើទេ?

ដែនៈ ផ្ញើ ។

សេងគា ៈ កាលយើងនៅស្រុកនឹង ម៉េចគេហៅប្រជាជនបញ្ញើរ ។

ដែនៈ គេថាដូចជាអ្នកមានធូរធាពីដើម ពីសង្គមចាស់ចឹងយើងមាន ពាក់ព័ន្ធ ។

អ្នកជិតខាងស្រីៈ ហើយត្រូវតាគេសម្លាប់ទៀត តាខាងខ្ញុំក៏សម្លាប់ តាខាងថៃ ខាងប្ដីក៏សម្លាប់ ។

សេងគា ៈ ម៉េចបានគេសម្លាប់ចោល?

ដែនៈ គេថាក្បត់នឹង ដឹងទៅថាណាវិញ ។

អ្នកជិតខាងស្រីៈ គាត់ក្បត់ចេះ កាលនឹងគេមិនបំបិទសាសនាចោល ហើយគាត់ដើរទិញលាក់ទិញអីយកមកជ្រលក់ជីពរលោក ។ ហើយដល់ហើយគេថាគាត់នឹងខ្មាំង ដើរទាក់ទង ។

ដែនៈ យកទៅវិរៃចោលនៅវត្តព្រះធាតុ ចង់គាត់ទុកចោលវត្តព្រះធាតុ ។

សេងគា ៈ ដល់ចឹងទៅមីងធ្វើការនៅកងនីងរហូតម៉ង?

ដែនៈ ធ្វើកងរហូត ។

សេងគា ៈ នៅជាប់ជាមួយមីងភីនឹងទេ?

ដែនៈ នៅមីងភី ។

សេងគា ៈ មីងភីនឹង កាន់កាប់នៅខាងណាខ្លះ មីងទៅកងណាខ្លះដែរ?

ដែនៈ ទៅកាន់កងនារីចឹងម៉ង ។

សេងគា ៈ កងនារីនៅម្តុំណា នៅធ្វើអី?

ដែនៈ ដើរគ្រប់ភូមិគ្រប់ឃុំនេះទៅស្រុកនេះស្រុកនោះ ទៅជីកប្រឡាយ ។

សេងគា ៈ មីងទៅបានប៉ុន្មានស្រុកដែរ មីងអាចចាំ?

ដែនៈ ខ្ញុំទៅកោះអណ្តែត ។

សេងគា ៈ កោះអណ្តែត ហើយទៅណាទៀត?

ដែនៈ កោះអណ្តែតទៅណាទៀត ទៅបៀតតានីនេះ គេហៅស្រុកអី កាលនឹងគេហៅ១០៩ ១០៥ ។

សេងគា ៈ ចឹងមុនដំបូងប៉ុន្មាន ១០៩?

ដែនៈ ១០៨នៅនោះ ស្រុកក្រោម ១០៥អានោះ ។

អ្នកជិតខាងស្រីៈ ១០៥ឯតានី ។

សេងគា ៈ ១០៥តានី ណាទៀត?

ដែនៈ អត់ដែលទៅណាទៀតទេ តែប៉ុននឹង ។

សេងគា ៈ ចឹង១០៥ ១០៨ ១០៩ ៣នឹងចល័តចុះឡើង?

ដែនៈ ចុះឡើង ។

សេងគា ៈ ដែលក្រុមមីងម៉ាកងនឹង មានគ្នាប៉ុន្មាននាក់?

ដែនៈ អី! ម៉ាកងនឹងច្រើន ។

សេងគា ៈ ប្រហែលប៉ុន្មាននាក់ទៅ?

ដែនៈ ម៉ាកងៗឡើងរយជាង ម៉ាកងៗ ។

សេងគា ៈ ហើយកាលនឹងអ្នកណាគេអ្នកក្តាប់ម៉ាកង?

ដែនៈ ក្រុម?

សេង៏គា ៖ បាទ! ប្រធានក្រុម ។

ជែនៈ អឺ! ប្រធានក្រុមដឹងអ្នកណាគេភ្លេចអស់ហើយ បង៏យ៉នមិនដឹង បង៏យ៉ននៅភូមិគោកព្រេច នឹង៏ ឥឡូវបង៏យ៉នទៅណា ។

សេង៏គា ៖ ចឹង៏នៅពេលដែលអ្នកមីង៏ធ្វើការចឹង៏ គេឲ្យហូបបបរៗម៉េចទៅ?

ជែនៈ ហូបបបរទឹកម៉ង៏ ។

សេង៏គា ៖ បបរទឹកម៉ាថ្ងៃប៉ុន្មានពេល?

ជែនៈ ម៉ាថ្ងៃ២ពេលនឹង៏ ពេលបាយថ្ងៃត្រង់ និង៏ថ្ងៃល្ងាចនឹង៏ ។

សេង៏គា ៖ ហើយហូបបបរនឹង៏ប៉ុន្មាន ដាក់កូនចានប៉ុនណាវែកនឹង៏?

ជែនៈ ម៉ាចានដាង៏ ដាក់ដែរៗដួសនៅតំរៀបគ្នាត្រែល ។

សេង៏គា ៖ ហើយរាវ ឬក៏ខាប់ដែរ បបរ១?

ជែនៈ វាមិនរាវពេកទេ វាធម្មតាតំរៀបគ្នាហែលៗចឹង៏ទៅមកដល់រត់ចូលម្នាក់ចានៗប្រុល ។

សេង៏គា ៖ ព្រោះឃើញខេត្តខ្លះនឹង៏គេដាក់ទឹកម៉ាគ្រាប់ ២គ្រាប់?

ជែនៈ អត់ទេ នេះធម្មតា មិនមែនអាប៉ក់ មិនមែនរាវពេកធម្មតា ទម្រាំដួសចប់ចាន ។

សេង៏គា ៖ ហើយមានសម្លគេដាក់សម្លអីឲ្យហូប?

ជែនៈ សម្លត្រកួនយើង៏នឹង៏ ត្រកួនព្រលិតៗដាក់ម៉ាដើម ។

សេង៏គា ៖ មីង៏កង៏របស់មីង៏គេហៅកង៏អី កង៏នារី?

ជែនៈ កង៏បង៏ភីនឹង៏?

សេង៏គា ៖ បាទ!

ជែនៈ កង៏ពិសេស ។

សេង៏គា ៖ កង៏ពិសេស គេយកទៅកន្លែង៏ណាដែលដាំដុះយកទៅ?

ជែនៈ កន្លែង៏ណាសំខាន់ៗគេទៅហើយកង៏ពិសេស ។១

សេង៏គា ៖ សំខាន់ៗធ្វើអី?

ជែនៈ ជីកប្រឡាយកម្លាំង៏ធំ ។

សេង៏គា ៖ ចឹង៏គេហៅកង៏ពិសេស?

ជែនៈ ហ្នឹង៏ហើយ ។

សេង៏គា ៖ ដឹកនាំដោយឈ្មោះ យ៉ននឹង៏?

ជែនៈ ចាំ!

សេង៉គា ៖ ហើយពេលទៅធ្វើរាល់ដង មានអត់ហើយដែនការអីទេ?

ដែនៈ គ្មានហើយចឹងទៅ ធ្វើទាលតែហើយៗ បើថាគេឲ្យជីកម៉ាម៉ែត្រចឹង ប្រឡាយនឹងក្នុងម៉ាក្រុមនឹង ១០ម៉ែត្រនឹង ធ្វើទាល់តែហើយបានឈប់ ។

សេង៉គា ៖ តែធ្វើអត់ហើយ?

ដែនៈ ធ្វើអត់ហើយ គេឲ្យធ្វើទាល់តែហើយ ។

សេង៉គា ៖ គេអត់មានដាក់ទណ្ឌកម្មអីទេ?

ដែនៈ អត់ទេ ។

សេង៉គា ៖ អត់មានថែមថ្ងៃនឹងអត់ហើយ១០ម៉ែត្រ ស្អែកឡើង២០ម៉ែត្រ មាន?

ដែនៈ ហ្នឹងហើយ អត់មាន ។

សេង៉គា ៖ ម្នាក់គេឲ្យជីកប៉ុន្មាន កាលនឹងគេគិតអ្នក?

ដែនៈ គេគិតអ្នក គេជីកក្រុមៗ ។

សេង៉គា ៖ ម៉ាក្រុមតូចៗទៀត ឬម៉េច?

ដែនៈ ក្រុមតូចៗ ក្រុម១០នាក់នឹង ។

សេង៉គា ៖ ១០នាក់គេឲ្យប៉ុន្មានម៉ែត្រ?

ដែនៈ ៥ម៉ែត្រចឹងទៅ ។

សេង៉គា ៖ បើជីករួចឈប់មុនគេទៅ?

ដែនៈ ចា៎! បើជីកហើយឈប់មុនគេទៅ ។

សេង៉គា ៖ ហើយនៅក្រោមឈ្មោះ យ៉ន នឹង មានអ្នកណាអនុប្រធាន?

ដែនៈ យ៉ន អត់ស្គាល់ទេ វាយូរពេកហើយ បើភ្លេច ។

សេង៉គា ៖ យ៉ននឹង គាត់នៅភូមិណាដែរ?

ដែនៈ នៅគោកព្រេច ឥឡូវគាត់មានប្ដី ទៅណាបាត់ទៅហើយ ឈប់នៅនឹង ។

សេង៉គា ៖ ហើយចុះដែលឃើញមីងផលនឹងទេ?

ដែនៈ ផល គាត់នៅស្រុកនឹងដែរ ។

សេង៉គា ៖ កាលនឹងមកល្អែងជួបគ្នាជាមួយគាត់ដែរ?

ដែនៈ ភី ហ្នឹង?

សេង៉គា ៖ បាទ! ភី ផលនឹង ។

ដែនៈ ផល នៅកំពែង ។

សេផគា ៖ មានដែលជួបគាត់ដែរ កផគាត់?

ជែនៈ អត់ដែលជួប គាត់ខាផចាស់ៗ ។

សេផគា ៖ ដល់ភីគាត់កាន់ខាផក្មេផៗ ?

ជែនៈ ចា៎! ក្មេផៗនារី បផភីគាត់កាន់ម៉ាស្រុក១០៩នឹផ គាត់កាន់នារី ហើយអឹផលគាត់ខាផចាស់ៗ តាមឃុំនឹផ ។ ដល់ពេលឃុំកំពែផចឹផ ឃុំគោកព្រេចនេះ ។

សេផគា ៖ ចឹផពេលចូល៧៦មកវិញ បានភីនឹផឲ្យចូលជាកផនារី?

ជែនៈ ចា៎! ចូលកផ ។

សេផគា ៖ ចូលកផនារី កផពិសេសទៀត?

ជែនៈ កផពិសេស ។

សេផគា ៖ នៅពេលនឹផហើយ មីផធ្វើការនឹផរហូត ឬក៏បផប្អូនបែកគ្នាអស់?

ជែនៈ បផប្អូន បែកគ្នាអស់ក្មេផ ។

សេផគា ៖ មីផដឹផថាបែកទៅខាផណាៗ ?

ជែនៈ មានតែទៅនៅស្រុកយើផដដែល គ្មានទៅណា ប្អូនៗនៅកុមារ?

សេផគា ៖ ប្អូនមីផស្រីចូលកុមារ?

ជែនៈ ចា៎!

សេផគា ៖ នៅតែមីផចូលខាផនឹផ?

ជែនៈ បផស្រីខ្ញុំគាត់នៅតាមសហករណ៍គេចឹផចាស់ៗ ។

សេផគា ៖ បផស្រីអាយុប៉ុន្មានបានគេឲ្យចូលសហករណ៍ចាស់ៗ ?

អ្នកជិតខាផប្រុសៈ ឲ្យតែអ្នកការហើយ ។

ជែនៈ ឲ្យតែអ្នកការហើយ មានប្តីមានប្រពន្ធ ។

សេផគា ៖ គេហៅពួកកសិករៗធ្វើការចាស់ៗម៉ផ?

ជែនៈ ចា៎!

សេផគា ៖ អ្នកដែលនៅលីវ ពួកយុវជនពួកនារី?

ជែនៈ ពួកយុវជន ពួកយុវនារី ។

អ្នកជិតខាផស្រីៈ ហើយដល់ពេលពួកខ្ញុំវ៉ាន់ កុមារ ។

សេផគា ៖ នៅពេលដែលមីផធ្វើការនឹផរហូត មីផមានដែលត្រូវគេធ្វើការអត់រួច គេស្តីឲ្យមានដាក់ទណ្ឌកម្ម?

ជែន៖ អត់ទេ ខ្ញុំអត់ដែរ ។

សេងគា ៖ មីងកាលនឹងគេឲ្យធ្វើអី?

ជែន៖ កាលមុននៅធ្វើប្រឡាយ ដល់មកនេះជិតរៀបប្ដេជ្ញានេះ ។

សេងគា ៖ កាលនឹងនៅឆ្នាំទីប៉ុន្មាន?

ជែន៖ មិនចាំទេ ដល់មកមិនសូវនឹកមិនសូវនារឿងចឹង ដល់គេឲ្យមកជីកប្រឡាយ ។

សេងគា ៖ បន្ទាប់ពីគេឲ្យមីងជីកប្រឡាយបានប៉ុន្មានខែ ប៉ុន្មានឆ្នាំ បានធ្វើជាកងខាងសេដ្ឋកិច្ច?

ជែន៖ មិនដឹងប៉ុន្មានឆ្នាំទេ ចុះមកពីខាងលើ ដល់ពេលដាំបាយដាំទឹក ដល់ពេលដាំបានម៉ាឆ្នាំនឹងក៏រត់មកស្រុកវិញ ។

សេងគា ៖ គេឲ្យដាំបាយ?

ជែន៖ ចា៎!

សេងគា ៖ ដាំបាយប្រហែលបានម៉ាឆ្នាំ៧៧ មីងការនឹង?

ជែន៖ អឺ! ការហើយបាន២-៣ខែរត់នឹង មកស្រុកយើងចឹង បរទេះសេះ ។

សេងគា ៖ ចឹងដល់១៩៧៧ ៧៦គេដាំបាយ?

ជែន៖ ដាំបាយ បរទេះសេះ មិនដាំទេ អ្នកបរទេះឲ្យគេដាំ ។

សេងគា ៖ ហើយចឹងមុនដំបូង វែកប្រឡាយ?

ជែន៖ វែកប្រឡាយ ។

សេងគា ៖ ដល់៧៧បានដាំបាយ?

ជែន៖ ដាំបាយ មិនដាំបាយទេ អ្នកបរទេះជីកអង្ករ ជីកអីឲ្យគេ អានឹងដោយសារខ្ញុំហើមដៃពេកក៏ឲ្យទៅនៅនឹង ជីកប្រឡាយអត់កើត ។ ចា៎! ដៃពស់ខាំ វាចេះតែហើម ។

សេងគា ៖ គេហៅកងសេដ្ឋកិច្ច អានឹងគេហៅថាម៉េចសម័យប៉ុលពតគេហៅថាម៉េច?

ជែន៖ អានឹងដឹងស្អីគេ ។

សេងគា ៖ អ្នកសេដ្ឋកិច្ចចឹងម៉ង?

ជែន៖ អឺ!

អ្នកជិតខាងស្រី៖ ធ្វើការ ពួកចល័តគេដើរធ្វើគ្រប់កន្លែងម៉ង គេមិនចាំតែម៉ាកន្លែងនឹងទេ ទៅណាក៏គេទៅដែរ ។

ជែន៖ គេឲ្យទៅណាទៅនឹង ។

សេងគា ៖ ម៉េចបានហើមដៃកាលនឹង?

ដែនៈ ពស់ចឹក នៅស្មាមទល់ឥឡូវ ពស់ខាំ ។

សេងគា ៖ ចុះហេតុអីបានពស់ចឹង គេប្រើទៅណា?

ដែនៈ ពស់ចឹងតាំងពីនៅមិនទាន់នោះ នៅក្រុមនៅស្រុក ហើយទៅរកក្តាមលូកទៅខាំទៅចេះហើម ដរហូតជាប់ ទើបមកជាឥឡូវ ។

សេងគា ៖ ទៅរកចាប់ក្តាម?

ដែនៈ ចាប់ក្តាម ។

សេងគា ៖ អ្នកណាគេប្រើឲ្យទៅរក?

ដែនៈ ម៉ែឪ ។

សេងគា ៖ ចឹងពេលពស់ខាំហើមដៃទៅ ក៏មន្ទីរឲ្យដូរទៅ?

ដែនៈ ឲ្យបរទេះ ។

សេងគា ៖ អានឹងបានស្រួលជាងមុន?

ដែនៈ ស្រួលជាងមុន ។

សេងគា ៖ ចុះហូបឆ្អែតទេ?

ដែនៈ ចុះនៅជាមួយគេហូបឆ្អែត ។

សេងគា ៖ ចុះមានដែលលួចរបស់របរមកឲ្យប្អូនមកឲ្យអីទេ?

ដែនៈ កាលនៅនោះលួចចេកលួចអីឲ្យម៉ែឪដែរ ។

សេងគា ៖ ចុះមានគេដឹងទេ?

ដែនៈ គេអត់ដឹង ។

សេងគា ៖ បើគេដឹង គេធ្វើបាបអត់?

ដែនៈ បើគេដឹង គេទម្លាក់យើងចេញអត់ឲ្យនៅកន្លែងទំនប់ ។

សេងគា ៖ បានលួចចេក លួចអីឲ្យ ចុះមានលួចអង្ករទៅឲ្យ ត្រី?

ដែនៈ អត់ហ៊ានទេ អង្ករ ។

សេងគា ៖ លួចបានចេកណាំវ៉ា?

ដែនៈ មិន ចេកទឹកយើងធម្មតា លួចម៉ែឪនៅកងសហករណ៍ចឹង យើងបរមកយើងលួចឲ្យម៉ាស្និត ២ស្និតទៅ ។

សេងគា ៖ ចឹងមីងភី គាត់ស្គាល់អ្នកភូមិ គាត់ជួយចឹង?

ដែនៈ មីងភី គាត់ស្គាល់អ្នកភូមិគាត់អត់មានកាចទេ ។

សេង៉គា ៖ ឲ្យតែអ្នកភូមិគាត់ជួយចឹង ពេលឈឺចឹង អត់មានបង្ខំឲ្យធ្វើការទេ?

ជែនៈ អត់ទេ ខ្ញុំនៅភូមិជាមួយគាត់ គាត់អាណិត គាត់ឲ្យធ្វើចឹងទៅ ។

សេង៉គា ៖ ហើយឥឡូវបានសេដ្ឋកិច្ច នៅជិតគាត់?

ជែនៈ នៅជាមួយគាត់ ។

សេង៉គា ៖ ចឹងសេដ្ឋកិច្ចនឹងនៅម្ដុំណា?

ជែនៈ នៅនេះ នៅភូមិសំរោងកើតនឹងដែរ កាលមុនគេធ្វើនៅនឹង ក្រុមកងគេនៅនឹង ។

សេង៉គា ៖ សំរោងខាងកើត កន្លែងនឹងរោងបាយ?

ជែនៈ ចា៎! រោងបាយ ។

សេង៉គា ៖ នៅជិតផ្ទះអ្នកណាគេ ឥឡូវ?

ជែនៈ នៅកន្លែងផ្ទះសៀប ខាងលើនឹង ។

សេង៉គា ៖ សៀប ប្រុសហើយស្រី?

ជែនៈ ស្រី ។

សេង៉គា ៖ ចឹងនៅពេលដឹកអន្ដរដឹកត្រីនឹង ដឹកទៅខាងណាខ្លះ មានចាំ?

ជែនៈ គ្មានដាក់តាមកងណា ដាក់តែម៉ាកងនឹងម៉ង ។

សេង៉គា ៖ កងនឹងឈ្មោះកងអី?

ជែនៈ កងពិសេសគេនឹង ។

សេង៉គា ៖ ដាក់បម្រើកងពិសេសដដែល?

ជែនៈ កងពិសេសនឹង ។

សេង៉គា ៖ អ្នកណាគេអ្នកប្រាប់ឲ្យដឹក?

ជែនៈ បងភីនឹងគាត់អ្នកចាត់ចែងចឹងទៅ ឲ្យដឹក ។

សេង៉គា ៖ ខាងចាត់ចែងអាហារដឹកទៅ?

ជែនៈ អឺ! តាមក្រុមតាមកងអីចឹងមក គាត់ប្រាប់ឲ្យទៅដឹក ។

សេង៉គា ៖ ចុះកងពេទ្យអីនោះមានដឹកទៅឲ្យ?

ជែនៈ គ្មានទៅទេ ពេទ្យគ្រប់គ្រងតែកន្លែង ។

សេង៉គា ៖ ចុះមីងមានដែរឈឺ?

ជែនៈ អត់ដែលឈឺ ។

សេង៉គា ៖ អត់ដែលបានទៅពេទ្យទៅអី?

ដែនៈ អត់មានទេ ។

សេងគា ៖ ចុះមន្ទីរពេទ្យនៅជិតមីង ឬក៏នៅឆ្ងាយ?

ដែនៈ មន្ទីរពេទ្យគ្មានណាផង ។ ពេទ្យតាគុណនឹងពេទ្យខាងកសិករ បើខាងនារីគ្មានណាទេ ។ គាយើបខាងពួកណាទេ មិនមែនពួកខ្ញុំ ។ គ្មានឃើញពេទ្យតាមទេខ្ញុំ ។

សេងគា ៖ អឺ!ប្រហែលមីងកងយុវជន អត់ដែលសូវឈឺអីចឹង សុទ្ធតែពួកនារី គេអត់មានពេទ្យ?

ដែនៈ អឺ! បើនៅតាមក្រុមសហករណ៍គេមានពេទ្យ ។

សេងគា ៖ ចឹងកាលនឹងមីងអត់ដែលឈឺអត់ដែលអី?

ដែនៈ អត់ដែល ។

សេងគា ៖ អត់មានប្រើថ្នាំ ប្រើអីទេ?

ដែនៈ អត់មានប្រើថ្នាំអីទេ ទទេរ ។

សេងគា ៖ ចឹងមីងធ្វើខាងសេដ្ឋកិច្ចនឹងប៉ុន្មានឆ្នាំដែរ? ប៉ុន្មានខែបានភីនឹងឲ្យការ?

ដែនៈ ម៉ាឆ្នាំនឹង បានដល់៧៨ ។

សេងគា ៖ ចឹង៧៨?

ដែនៈ ចាំ!

សេងគា ៖ ចឹង៧៨ភីនឹងរៀបការឲ្យ?

ដែនៈ ចាំ! រៀបការឲ្យ ។

សេងគា ៖ រៀបការឲ្យជាមួយពីណាគេ?

ដែនៈ ជាមួយប្តីរាល់ថ្ងៃ ឃួន សុខុន ។

សេងគា ៖ កាលនឹងមានស្គាល់គ្នាជាមួយប្តីទេ?

ដែនៈ អត់ស្គាល់ គេចាប់ដាក់ម៉ង ។

សេងគា ៖ ចាប់ដាក់ កាលនឹងប្តីធ្វើអី?

ដែនៈ ធ្វើយុវជនដែរ ប៉ុនឪ(ប្តី)កាលនឹងជាប់គុក ចេញពីគុកបានតែ២ខែ ។

សេងគា ៖ អ្នកណាគេ?

ដែនៈ ប្តីខ្ញុំនឹង កាលអាពត ។

សេងគា ៖ ជាប់គុកនៅណា?

ដែនៈ នៅវត្តព្រះធាតុនេះ ។

សេងគា ៖ ចឹងគេឲ្យរៀបការមីងអត់ដែលស្គាល់ពីមុនមកទេ ហើយគេឲ្យនឹង មានប្រកែកទេ?

ដែនៈ ប្រកែកក៏មិនរួច អ្នកគេស្នើលើកមុនគេអត់ឲ្យ ។

សេងគា ៖ ហើយកាលនឹងការប៉ុន្មានគូដែរ?

ដែនៈ កាលការ៣ថ្ងៃនឹង មុនដំបូង៥០គូ ខ្ញុំទៅធ្វើភ្ញៀវគេដែរ ។

សេងគា ៖ ហើយមីងការក្រោយ?

ដែនៈ ខ្ញុំការក្រោយគេបន្តស់ ។

សេងគា ៖ ម៉ាថ្ងៃការ៥០គូ?

ដែនៈ ៥០គូ ក្រោយមក៤០ ដល់ថ្ងៃអ៊ីនោះតែ៣០ទេ ។

សេងគា ៖ ហើយការគេធ្វើម៉េចខ្លះទៅ?

ដែនៈ មានធ្វើម៉េច ឲ្យអង្គុយត្រង់ភ្លីងចឹងគេហៅចាប់ មុនដំបូងគេដូរកន្សែងគ្នាទៅវិញទៅមក ស្គាល់មុខគ្នា ។

សេងគា ៖ ក្រមាពណ៌អី?

ដែនៈ ខ្ញុំក្រមាសូត្រ ឪមាយយកក្រមាខ្ញុំអត់ឲ្យវិញ ដល់ចឹងគេដាក់ដ្ការំយោលក្រហម១៣កែវ ស្រាប់គេឲ្យអង្គុយមុខគ្នាចឹង ដល់ពេលនឹងគេហៅម្នាក់ម៉ាគូ ឡើងទៅកន្លែង គេអ្នកឈរគុ នឹង គេអ្នកប្តេជ្ញាជំនួសយើងទាំងអស់គ្នានឹង មុនម៉ាគូចឹង ចាប់ដៃគ្នាដើរចេញៗ ។

សេងគា ៖ មីងទៅដល់ជាមួយនិងពូនឹង ទៅដល់ឃើញគ្នាចាប់ដៃគ្នា?

ដែនៈ គ្មានឃើញទេ គេហៅលេខឈ្មោះទល់មុខចឹង ។

សេងគា ៖ គេផ្គូផ្គងហើយៗរួចអស់ហើយ?

ដែនៈ ហ្នឹងគេផ្គូផ្គង់ហើយៗ មុនគេហៅ ។

សេងគា ៖ ហើយកាលពេលឃើញពូដំបូង ស្រឡាញ់ពូដែរ ឬអត់ទេ?

ដែនៈ ហ៎! អត់ស្រឡាញ់ៗតាំងពីដើមមកចឹង និយាយដោយត្រង់ទើបដើរចុះមកពីលើវិញ បានត្រូវគ្នា ប៉ុនគ្មានអ្នកណាដឹងទេ ។ គ្មានអ្នកណាដឹងថាយើងមិនត្រូវគ្នានទេ បើសិនមិន ត្រូវគ្នាដឹងថាគេធ្វើបាប ។

សេងគា ៖ ដល់ពេលការហើយនៅជាមួយគ្នាបានប៉ុន្មានថ្ងៃ បានបែកគ្នា?

ដែនៈ បាន២ខែៗ បានរត់ ។

សេងគា ៖ ចុះនៅបែកគ្នាទេ?

ដែនៈ នៅបែកគ្នាគេៗ ។

សេងគា ៖ ប្តីធ្វើការនៅកងណាដែរ?

ដែនៈ កងយុវជន ។

សេងគា ៈ យុវជននៅខាងភូមិអី?

ដែនៈ នៅជាមួយគ្នា ចល័តកងយុវជន យុវនារីទាំងអស់ ។

សេងគា ៈ ពិសេសដូចគ្នា?

ដែនៈ ហ្នឹងហើយ ។ ប៉ុនដល់មកនៅក្រុមសហករណ៍ នៅដោយខ្លួនហើយ អ៊ីគេឲ្យទៅកាប់ប្រើយ៍ (សម្រាប់ប្រក់ផ្ទះ) នៅភ្នំក្រពើទៅ ។

សេងគា ៈ កាត់អីវិញ?

ដែនៈ កាប់ប្រើយ៍ ។

សេងគា ៈ កាលនៅព្រៃ គេឲ្យកាប់ព្រៃ?

ដែនៈ ចាំ! បានមានប្ដីហើយ ។

សេងគា ៈ គេឈប់ឲ្យមឹងកាន់ខាងសេដ្ឋកិច្ចហើយ?

ដែនៈ ឈប់ហើយ មកនៅកសិករហើយ ។

សេងគា ៈ ដល់មានប្ដីដូរមកកសិករវិញ?

ដែនៈ ចាំ! កសិករវិញ ។ កាលនឹងប្ដីនៅដោយខ្លួន ប្រពន្ធនៅដោយខ្លួនទៀត មិននៅជាមួយគ្នាទេ ។

សេងគា ៈ គេប្ដូរមកកសិករវិញ?

ដែនៈ ចាំ!

សេងគា ៈ ចឹងគេប្ដូរមកនេះវិញ ទៅខាងណាកាប់ព្រៃខាងណា?

ដែនៈ ប្រូតប្រើយ(សម្រាប់ប្រក់ផ្ទះ) នៅខាងភ្នំក្រពើ ។

សេងគា ៈ ចុះព្រៃម៉េចប្រូតវិញ?

ដែនៈ ប្រើយយើងប្រក់ផ្ទះ គេប្រូតឲ្យវាលចឹងអាងគេយកដីធ្វើស្រែឲ្យប្រូតអានឹង ។

សេងគា ៈ នៅភ្នំអីគេ?

ដែនៈ ភ្នំក្រពើ ។

សេងគា ៈ ទៅទាំងពីរនាក់ប្ដីប្រពន្ធ?

ដែនៈ ទៅ ប៉ុនប្ដីធ្វើដោយខ្លួនចឹងទៅ ។

សេងគា ៈ ប្ដីនៅកងយុវជនដដែល អត់ទាន់បំបែកទេ?

ដែនៈ កងកសិករនឹងដែរ ប៉ុននៅខាងផ្នែកប្រុសៗ ។

សេធគា ៖ ប៉ុន្តែមីងស្រីទៅខាងនោះ?

ជែន៖ ចា៎!

សេធគា ៖ ឯប្តីនៅខាងកសិករ ធ្វើអីដែរ?

ជែន៖ កាលនឹងគេជីកប្រឡាយដែរ ។

សេធគា ៖ ចឹងមកជុំគ្នាវិញ ឬក៏បែកគ្នាយប់ឡើង?

ជែន៖ បែកគ្នាៗយប់ឡើងមិននៅដល់ថ្ងៃអាទិត្យ ថ្ងៃព្រហស្បតិ៍បានគេឲ្យជួបគ្នា ។

សេធគា ៖ ម៉ាអាទិត្យគេឲ្យជួបគ្នាប៉ុន្មានដង?

ជែន៖ ម្តងនឹង ។ ប៉ុនខ្ញុំគ្មានបានជួបគ្នាទេ បែកគ្នារហូត ។

សេធគា ៖ បែកគ្នារហូត?

ជែន៖ ចាស ។

សេធគា ៖ ចឹងមីងនៅ៧/៨ច្រូតព្រៃហ្នឹងរហូតចឹង?

ជែន៖ ចាស!ទៅច្រូតព្រៃបានតែប៉ុន្មានថ្ងៃហ្នឹងគេឲ្យទៅជីកប្រឡាយវិញហើយ ។

សេធគា ៖ ចឹងបន្ទាប់មកជីកប្រឡាយនៅណាវិញ?

ជែន៖ ទៅស្ទឹងនោះដីប្តី ភ្នំដីប្តី ។

សេធគា ៖ ភ្នំឈើប្តី?

ជែន៖ ចាស!ភ្នំឈើប្តីនៅយើងស្រុកយួនហ្នឹង ។

សេធគា ៖ ដាវប្តី?

ជែន៖ ចាស!ដាវប្តីមកវិញស្រុកចឹងតែម្តង ។

សេធគា ៖ ចឹងពូថាប្តីមីងជាប់គុកនៅគុកប្រធាតុនោះយ៉ាងម៉េច?

ជែន៖ គាត់ជាប់នៅគុកប្រធាតុហ្នឹង តាំងពីមុនជួបគ្នានោះ ។

សេធគា ៖ អរ!តាំងពីមុនជួប?

ជែន៖ ចាសៗ!គ្រាន់តែចេញមកបានពីរខែរៀបការតែម្តង ។

សេធគា ៖ គេឲ្យរៀបការយ៉ាងម៉េចខ្លះ?

ជែន៖ រៀបការថា ចាប់ដៃគ្នាសុខចិត្តតស៊ូជាមួយគ្នាចឹងទៅរៀបការយកគ្នាមួយជីវិតចឹងទៅ តែខ្ញុំគេមានឲ្យនិយាយទេ គេមានអ្នកជំនួសម្នាក់១០គូរទៅ២០គូរហ្នឹង ។

សេធគា ៖ ចឹងប្តីមីងនៅផ្ទះតើ?

ជែន៖ អត់ទេ គាត់ទៅធ្វើការនៅបន្ទាយមានជ័យ ។

សេងគា ៖ ស្មានណាគាត់មកវិញ?

ជែនៈ មិនមកទេ មិនដែលមកទេ រាប់ឆ្នាំ ។

សេងគា ៖ អរ!នៅណា នៅបន្ទាយមានជ័យ?

ជែនៈ នៅបន្ទាយមានជ័យ ។

សេងគា ៖ អរ!នៅបន្ទាយមានជ័យបាត់ដំបងជិតខេត្តខ្ញុំហ្នឹង ។

ជែនៈ ចាស ។

សេងគា ៖ ចឹងគាត់អត់មកទេ គាត់មានលេខទូរស័ព្ទទេ ចង់ខលសួរគាត់តាមទូរស័ព្ទអីបានទេ?

ជែនៈ មាន អីមានខ្ញុំក៏មានដែរ ។

សេងគា ៖ បាទ!ចឹងខ្ញុំសុំលេខទូរស័ព្ទគាត់បន្តិចមក ខ្ញុំអាចចង់ដឹងពត៌មានខ្លះខ្ញុំខលទាក់ទងគាត់ណាស់ ព្រោះឆ្ងាយពេកទៅឆ្ងាយណាស់ ។

ជែនៈ ទាក់ទងរឿងប្រវត្តិជាប់គុកហ្នឹង ។

សេងគា ៖ បាទ!ចង់ដឹងពីរឿងគុកហ្នឹង ។

ជែនៈ ០៩២ ២៦៨៨៧២ ។

សេងគា ៖ ០៩២ ២៦៨៨៧២ ។

ជែនៈ តែមិនស្រួលគេបិតហើយទឹងខ្ញុំកាលពីថ្ងៃមុន ទឹងកូនទឹងខ្ញុំប្រាប់ថាឈប់ឲ្យទាក់ទងគេគេបិតលេខទូរស័ព្ទ ។

សេងគា ៖ ហើយប៉ុន្មានខែគាត់មកលេងផ្ទះម្តង?

ជែនៈ ៥ខែចឹងទៅ ៦ទៅ៧ខែ ។

សេងគា ៖ ធ្វើប៉ូលីសអីបានឆ្ងាយម្លេះ?

ជែនៈ កាលមុនប៉ូលីសនៅភ្នំដិននេះ ដល់ហើយគេផ្លាស់ទៅហ្នឹង ផ្លាស់ទៅហ្នឹង៨ទៅ៩ឆ្នាំហើយ ។

សេងគា ៖ ដល់ចឹងទៅមីងជីកប្រឡាយរហូតដល់បែកគ្នាចឹងទៅ?

ជែនៈ ចាស!បែក ។

សេងគា ៖ ដល់បែកគ្នាចឹង កំពង់តែបែកហ្នឹងដែលជួបមីងភីទៀតទេ?

ជែនៈ អត់ដែលទេ អូន ។

សេងគា ៖ មិនដែលជួបទេ?

ជែនៈ មិនដែលជួបសោះ ។

សេងគា ៖ ចឹងពេលមីងទៅច្រូតព្រៃឬមីងទៅជីកប្រឡាយនៅជាវប្តីអីហ្នឹង?

ដែនៈ ចាស ។

សេងគា ៖ មីងមានដែលឃើញគេធ្វើបាបមនុស្សអីឬក៏អីអ្នកផ្សេងធ្វើ?

ដែនៈ គ្មានទេនៅតាមកងនារីៗចាស់ចឹង មិនដែលឃើញទេ បើសិនជានៅតាមផ្ទះតាមអីហ្នឹងក្រុងយើងដឹងណាអូន ។

សេងគា ៖ បាទ ។

ដែនៈ អត់មានតាមនារីៗហ្នឹងអត់មានព្វអីទេ ។

សេងគា ៖ ហើយពេលទៅដល់កងកសិករមិញហ្នឹងគេឲ្យហូបឆ្អែតទៅឬមួយក៏យ៉ាងម៉េច?

ដែនៈ ហូបដូចគ្នាបបរចឹងដូចគ្នា ។

សេងគា ៖ បបរដូចគ្នាបានមកនៅសេដ្ឋកិច្ចបាននេះ ដល់មានគ្រួសារទៅលំបាកវិញ?

ដែនៈ លំបាក ស៊េច... កាលនៅនេះស្រុកបានតែប៉ុន្នានហ្នឹង ។

សេងគា ៖ ចឹងមីងមានដឹងទេ ថាហេតុយ៉ាងម៉េចបានមីងភីចេះតែចាប់គូរឲ្យរៀបការចឹង?

ដែនៈ ទេ មិនដឹងជាដែនការគេយ៉ាងម៉េចមិនដឹងទេ ។

សេងគា ៖ មីងមិនដឹងទេ តែមីងនៅគៀកគាត់ដែលមិនដឹងទេ?

ដែនៈ មិនសូវគៀកទេ ខ្ញុំនៅកន្លែងគេនៅដោយខ្លួនចឹងទៅ មិនអ្នកណា ។

សេងគា ៖ បាទ!ចឹងគេឲ្យរៀបការ កាលហ្នឹងរៀបការនៅម្ដុំណាកាលហ្នឹង?

ដែនៈ នៅត្រពាំងរុន ។

សេងគា ៖ ត្រពាំងរុន?

ដែនៈ អ្នកជិតនិយាយថា"គេឲ្យរៀបការវាដល់អាយុគេ" ។ ដែន និយាយថា"គ្មានដល់អាយុណាទេ វាចាប់ដាក់វានឹកឃើញយ៉ាងម៉េចវាចាប់ចឹង ។

សេងគា ៖ ត្រពាំងរុនភូមិឃុំអីគេ?

ដែនៈ ឃុំរាមអណ្ដើក ។

សេងគា ៖ ឃុំរាមអណ្ដើក?

ដែនៈ ចាស ។

សេងគា ៖ មីងមុនជំបូង៣០អះ!៥០?

ដែនៈ ៥០ក្រោយមក៤០ កាលអ៊ីតា៣០ ។

សេងគា ៖ ចឹងកាលមីងការហើយប្ដីមីងមិនបានជុំគ្នាទេ?

ដែនៈ នៅ ។

សេងគា ៖ នៅពេលបែកមកវិញបានជួបគ្នា?

ដែនៈ នៅជាមួយគ្នាតែយើងមិនសូវស្រឡាញ់គ្នា អត់សូវមកជួបគ្នា ។

សេងគា ៖ ចឹងកាលមីងការអត់មានស្រឡាញ់គ្នាទេ?

ដែនៈ អត់ទេ ។

សេងគា ៖ ហើយចេះតែបន្ទុំចិត្តនៅជាមួយគ្នាទៅ?

ដែនៈ នៅជាមួយគ្នាទឹសមកដល់ស្រុកចឹងបានត្រូវគ្នា ។

សេងគា ៖ ចឹងទាល់តែស្រុកសន្តិភាពវៀតណាមរំដោះបានហើយបានត្រូវគ្នា?

ដែនៈ ចាស ។

សេងគា ៖ ដល់ត្រូវគ្នាបានមានកូនចៅទៅ?

ដែនៈ ចាស ។

សេងគា ៖ កាលមុនអត់ត្រូវគ្នាអត់មានកូនចៅទេ?

ដែនៈ អត់មានកូនចៅ ។

សេងគា ៖ ចឹងកាលហ្នឹងមួយអាទិត្យគេឲ្យជួបគ្នាម្តង ចេះតែនៅជាមួយគ្នាទៅ ។

ដែនៈ ចាស ។

សេងគា ៖ តែអត់មានទេ?

ដែនៈ មិនទាន់បានដែលមកផង បើទើបប៉ុណ្ណឹងខែ ប្តេជ្ញាបានតែពីរខែបែកគ្នារត់ចឹងទៅ ។

សេងគា ៖ ចឹង៧៨ហ្នឹងចុងខែហើយ ដល់៧៩ហ្នឹងដល់ថ្ងៃទី៧មករារំដោះហើយ ចឹងចុងខែមីងណើស ។

ដែនៈ ចាស ។

សេងគា ៖ ចឹងនៅចុងឆ្នាំហើយ ។

ដែនៈ ចាស ។

សេងគា ៖ ចឹងបែកគ្នារហូតមីងមានបងប្អូនស្លាប់នៅក្នុងសម័យប៉ុល ពតហ្នឹងទេ?

ដែនៈ ប្អូនខ្ញុំស្លាប់មួយ ។

សេងគា ៖ ប្អូនស្លាប់កាលហ្នឹង?

ដែនៈ ចាស ។

សេងគា ៖ ស្លាប់ដោយសារអី?

ដែនៈ វាធ្វើធ្វើពេទ្យទាហានអាពត វាអាពតដែលហ្នឹង ។

សេងគា ៖ ពេទ្យទាហានអាពតដែរ?

ដែនៈ ហ្នឹងហើយ ។

សេងគា ៈ យ៉ាងម៉េចបានស្លាប់?

ដែនៈ ស្លាប់ត្រូវគ្រាប់តាមទ័ពស្រុកយួននោះ ។

សេងគា ៈ អ!តាមទ័ពនៅស្រុកយួន?

ដែនៈ ហ្នឹងហើយ ។

សេងគា ៈ ប្អូនដែលស្លាប់ហ្នឹងឈ្មោះអី?

ដែនៈ ឈ្មោះប្រុស ។

សេងគា ៈ ឈ្មោះប្រុស?

ដែនៈ ចាស ។

សេងគា ៈ ចឹងយ៉ាងម៉េចបានមីងដឹងថាគាត់ស្លាប់?

ដែនៈ គេនៅកង១ទ័ពដឹងគេមកប្រាប់ ។

សេងគា ៈ កងទ័ពហ្នឹងមាននៅចាំឈ្មោះទេ?

ដែនៈ ភ្លេចអស់ហើយពួកអស់ហ្នឹង ខ្ញុំទៅនៅជីកប្រឡាយនៅហ្នឹង«អ្នកជិតខាងនិយាយថា សៅ ជន ដែននិយយវិញថា ជន សៅ ជន ។

សេងគា ៈ ប្រុសស្រី?

ដែនៈ ប្រុសវាកងអាពតដែរ ។

សេងគា ៈ ចឹងសៅ ជន?

ដែនៈ ចាស ។

សេងគា ៈ ចឹងបានប្រាប់រួចអាពតហើយបានប្រាប់ឬក៏យ៉ាងម៉េច ដល់រំដោះហើយបានប្រាប់ឬក៏យ៉ាងម៉េច?

ដែនៈ នៅពេលរំដោះហើយមកចឹង«អ្នកជិតខាងនិយាយថា ៧៩ហើយបានគេនិយាយថា បាត់កូនមិនដែលឃើញមកចឹងទៅណាស់» ដែននិយាយថា បាត់កូនបាត់ប្អូនមិនឃើញមកគេប្រាប់ចឹងទៅ ។

សេងគា ៈ ចឹងមីងមានដែលឃើញគេធ្វើទារុណកម្មដាក់អ្នកណាម្នាក់ទេ?

ដែនៈ អត់ ។

សេងគា ៈ ស្លាប់អត់មានទេ?

ដែនៈ អត់មានដែលឃើញ វាពេលណាដឹងគ្នាខ្លាចចង់ងាប់ចង់រស់ ។

សេងគា ៖ ចឹងអត់អីទេ ចឹងខ្ញុំអត់មានអីសួរមីងទៀតទេ ។

ដែនៈ ចាស ។

សេងគា ៖ ខ្ញុំអរគុណមីងច្រើនដែលមីងបានរៀបរាប់រឿងរ៉ាវខាងខ្ញុំចឹង ។

ដែនៈ ចាស ។

សេងគា ៖ ចឹងមីងដល់ចូលមកវិញកូនចៅមានរៀនទៀតទេឬអត់ទេ?

ដែនៈ ខ្ញុំហ្នឹង ។

សេងគា ៖ បាទ ។

ដែនៈ អត់មានរៀនអីទេ?

សេងគា ៖ អត់បានរៀនអីទេ កាលហ្នឹងមីងក៏មានដឹងថា មីងចេះអក្សរអីទេ?

ដែនៈ ជីមិនដឹង ។

សេងគា ៖ ដឹងដែរ?

ដែនៈ ចាស ។

សេងគា ៖ ដឹងហើយព្រុថាអ្នកចេះចឹងគេសម្លាប់ចោលចឹង មីងម៉េចបានជាអត់អីចឹង?

ដែនៈ ចុះយើងថ្នាក់តូចតាចប៉ុណ្ណឹងមិនទាន់អីទេ ។

សេងគា ៖ ចឹង?

ដែនៈ ចាស ។

សេងគា ៖ មីងនៅហ្នឹងជាប្រជាជនបញ្ញើរទេ?

ដែនៈ ប្រជាជននៅស្រុកផ្ញើតែយើងរាងទ្រុងធូរធារគេដាក់យើងផ្ញើចឹងទៅណាស់ ។

សេងគា ៖ បាទ ។

ដែនៈ បើអ្នកក្រីក្រគេដាក់ពេញសិទ្ធចឹងទៅ ។

សេងគា ៖ ចឹងមីងមានដែលសួរពីរឿងប្ដីមីងរឿងជាប់គុកអីទេ ដឹងថាប្ដីមីងធ្លាប់ជាប់គុកអីចឹង?

ដែនៈ អីមិនដឹងចេញមកក៏គាត់ប្រាប់ដែរ ។

សេងគា ៖ គាត់ប្រាប់ថាយ៉ាងម៉េចខ្លះទៅកាលចេញមកភ្លាម?

ដែនៈ ប្រាប់ថា ជាប់គុកព្រោះលួចអង្ករឲ្យប្អូនស៊ី ។

សេងគា ៖ ចឹងលួចអង្ករឲ្យប្អូនស៊ីជាប់គុកដែរ?

ដែនៈ យី! គេចាប់បាន ។

សេងគា ៖ ចឹងយ៉ាងម៉េចទុកអង្ករឲ្យលួចបាន ប្អូនបានអង្ករពីណាមក?

ដែនៈ លួចអង្កយកមកចិញ្ចឹមប្អូន ។

សេងគា ៖ អរ!លួចអង្កយកមកចិញ្ចឹមប្អូន?

ដែនៈ ព្រោះគ្នាកំព្រាគ្មានម៉ែគ្មានឪ ។

សេងគា ៖ ស្មានថា លួចពីប្អូន?

ដែនៈ អត់ទេ ឪវាអាពតយកវៃចោល បាបមាំណាស់រំកោស៊ូហើយចងជ្រមុជទឹកទៀតណាស់ ឪប្ដីខ្ញុំហ្នឹងណាស់ នៅភ្នំរុនទះហ្នឹង ឪក្មេកហ្នឹង ។

សេងគា ៖ បាទ ។

ដែនៈ ពីដើមគាត់សក្ដិ២ ពីសង្គមចាស់ណាស់ ដល់នេះគេយកវៃចោល ។

សេងគា ៖ កាលលួចអង្កហ្នឹងលួចអង្កនៅណាដែរ?

ដែនៈ នៅទន្លាប់ កាលហ្នឹងគាត់ធ្វើកងនៅទន្លាប់ ។

សេងគា ៖ ធ្វើកងនៅទន្លាប់ហើយលួចអង្កនៅរោងបាយ?

ដែនៈ ហ្នឹងហើយ សើច... ។

សេងគា ៖ លួចអង្កនៅរោងបាយនរណាជាអ្នកចាប់បានកាលហ្នឹង?

ដែនៈ ពួកទ័ពគេពួកឈ្លបអីគេហ្នឹង ។

សេងគា ៖ ពួកឈ្លបគេហ្នឹង គាត់មានប្រាប់ឈ្មោះទេ?

ដែនៈ មិនដឹងខ្ញុំមិនដឹងទេ គាត់និយាយប្រាប់បន្តិចៗ ។

សេងគា ៖ ចុះកាលហ្នឹងទៅទន្លាប់សោះម៉េច?

ដែនៈ គេបញ្ជូនមកប្រធាតុហ្នឹង ។

សេងគា ៖ គេបញ្ជូនមកប្រធាតុហ្នឹង?

ដែនៈ ហ្នឹងហើយ ដើងជាប់ខ្នោះរហូត ។

សេងគា ៖ គាត់មានប្រាប់ជាប់ខ្នោះយ៉ាងម៉េចខ្លះដែរ?

ដែនៈ ជាប់ខ្នោះដាក់ជើងមួយវាថាត្រូវប៉ូកៗត្រូវវាផ្ទាំៗអាចម៍នោមចូលជាមួយគ្នាហ្នឹង ។

សេងគា ៖ អាចម៍នោមហ្នឹងដែរ?

ដែនៈ គេថាយកត្រឡោកដាក់បាយមកឲ្យ យកបបរដាក់ត្រឡោកមកឪវាថា យកត្រឡោកដាក់បបរ ដាក់ត្រឡោកមកឲ្យស៊ីៗ ហើយតាមួយនៅក្បែរគាត់និយាយថា វាកាន់ទ្រាប់អាស្វីកពោធិ៍ ស្វីកពោធិ៍ខ្ញីៗហ្នឹង ទ្រាប់ឆ្នាំងចានមកដល់ហើយតាហ្នឹង ទាញកាយហូបៗស្វីកពោធិ៍ហ្នឹង ដល់ពេលមួយថ្ងៃនោះ តា ហ្នឹងនៅស្រុកជាមួយវាដែរ ថាគាត់រងាហើយគ្មានបាយ

ស៊ីគាត់ដោះអាវខ្លួនគាត់ហ្នឹងដូរបាយគេហូប ដូរបាយក្នុងហ្នឹងហូបបានយប់ឡើងគាត់រងាវែខ កក្តិកនោះ គាត់ស្លាប់នៅចំណងជើងទល់គ្នាហ្នឹង ។

សេងគា ៖ កាលហ្នឹងគេអត់មានដោះអាវទេ?

ជែន៖ ចាស!ដល់ពេលនេះគាត់ដូរបាយហូប គាត់ឃ្លាននោះ ។

សេងគា ៖ កាលហ្នឹងគាត់មានប្រាប់ថា ប្រធានគុកជាពីណាគេទេ?

ជែន៖ ប្រធានគុកមិនដឹងជាពីណាទេ ។

សេងគា ៖ មឹងមានចាំឈ្មោះទេ?

ជែន៖ អត់មានដឹងពីណាប្រធានទេ ខ្ញុំមិនសូវដឹង ។

សេងគា ៖ កាលហ្នឹងគេឲ្យហូបបាយយ៉ាងម៉េចដែរ ហូបបាយ?

ជែន៖ ហូបបបរដែលដាក់ត្រឡោកឪវាថា ។

សេងគា ៖ គេឲ្យហូបប៉ុន្មានពេលទៅជាប់គុកចឹង?

ជែន៖ អត់ដឹង អត់បានសួរគេ ។

សេងគា ៖ ចឹងគាត់មានបានប្រាប់ថា គុកហ្នឹងមានច្រើនទេ មានអ្នកជាប់ច្រើនទេ?

ជែន៖ មានច្រើន ។

សេងគា ៖ ចឹង?

ជែន៖ ជាប់ច្រើន?

សេងគា ៖ ហើយគាត់ប្រាប់យ៉ាងម៉េចទៀតទៅ?

ជែន៖ គាត់មានប្រាប់ម៉េច ប្រាប់ថាគាត់វេទនាចឹង ។

សេងគា ៖ គាត់ថាជាប់ប៉ុន្មានខែ?

ជែន៖ ឪវាជាប់យូរដល់ពេលរត់ទៅលើហ្នឹង រត់ទៅលើមួយសារហ្នឹងទៅជាមួយគេហ្នឹងមកវិញគេ ដាក់គុកទៀត មកមួយសារទៀត ។

សេងគា ៖ អរ!ដាក់គុកមួយសារទៀត?

ជែន៖ ចាស! ដល់បានមកដល់នេះ មិនដឹងជាយ៉ាងម៉េចបានឪវាចេញ ។

សេងគា ៖ គេអត់មានយកទៅសម្លាប់ចោល?

ជែន៖ មិនដឹងជាយ៉ាងម៉េច សំណាងឪវា ។

សេងគា ៖ កាលហ្នឹងអ្នកទោសភាគច្រើនគេមិនសូវទុកទេ?

ជែន៖ ដល់ពេលមកវិញវាឲ្យ អាយុវាមិនអស់ ដល់ពេលចេញមកវិញខំធ្វើការល្អចេះតែធ្វើទៅ ។

សេង៉គា ៖ ចឹងកាលហ្នឹងជាប់គុកពីរដង?

ដែន៖ ពីរដង ។

សេង៉គា ៖ អាមុនហ្នឹងជាប់នៅឆ្នាំណាមានចាំទេ?

ដែន៖ អត់ដឹងទេ ដល់រត់មកវិញហ្នឹងគេនាំទៅលើចឹង គេនៅតាមគ្នាគេជាប់រហូតហ្នឹងដល់ចុះមកជាប់គុកវិញដដែល ។

សេង៉គា ៖ គាត់មានបានប្រាប់ទេថា ជើងទាំងពីរជាប់ខ្នោះឬមួយជាប់តែមួយចំហៀងទេ?

ដែន៖ ជាប់តែម្ខាងទេ ឲ្យយើងត្រឡាប់បាន ។

សេង៉គា ៖ ជាប់ម្ខាងខាងឆ្វេងខាងស្តាំ?

ដែន៖ មិនបានដឹងអត់មានសួរគេផង ។

សេង៉គា ៖ ចឹងអត់មានមើលជើងជាប់ជាំ?

ដែន៖ អត់មានបានពិនិត្យមើលគេ តែដៃស្ពឹកម្ខាងហើយគេចង ។

សេង៉គា ៖ អរ!គេចងដៃយ៉ាងម៉េចទៅ?

ដែន៖ ចងស្លាបសេកកាលដែលបញ្ជូនមកនោះ ។

សេង៉គា ៖ គេចងស្លាបសេក?

ដែន៖ ហ្នឹងហើយជិះម៉ូតូអីវ៉ាថា ស្ពឹកដល់តែក្រឡាស់ចឹងបានបាត់ ។

សេង៉គា ៖ ចឹងជាប់ពីរដងគាត់ថា ជាប់យូរ?

ដែន៖ ជាប់ដឹងជាប៉ុន្មានឆ្នាំទេ អត់មានសួរគេផងយូរ ។

សេង៉គា ៖ គាត់ធ្វើប៉ូលីសនៅបន្ទាយមានជ័យស្រុកអីខេត្តអី ស្រុកអីដែរ?

ដែន៖ មិនដឹងជាស្រុកអីមិនដែលសួរគេ«អ្នកជិតខាងនិយាយថា ធ្វើប៉ូលីសទៅបឹងត្រកួនហ្នឹងខេត្តអី» ។

សេង៉គា ៖ នៅបឹងត្រកួន ខ្ញុំដូចជាអត់ច្បាស់ដែលភូមិវ៉ាច្រើនពេក ចឹងនៅបឹងត្រកួនបន្ទាយមានជ័យខ្ញុំស្គាល់ហើយមីងឲ្យឈ្មោះ ចឹងប្រាប់មីងតែប៉ុណ្ណឹងទេ?

ដែន៖ ចាស!ខ្ញុំអត់សួរដើម សួរទងគេខ្ជិល ។

សេង៉គា ៖ ចឹងមីងកាលបែកភ្លាមៗចាប់ផ្តើមស្រឡាញ់ប្តីហើយឬមួយមិនទាន់ស្រឡាញ់ទេ?

ដែន៖ សើច... ។

សេង៉គា ៖ បើតាមមីងនិយាយដូចជាមិនសូវស្រឡាញ់ប្តី?

ដែន៖ កាលហ្នឹងមិនសូវស្រឡាញ់ទេ ដល់ពេលចុះមកពីលើហ្នឹង ចុះមកឃើញគេចាប់ចងនោះ

កាលជិនាទ់ហ្នឹងគេមិនសួរ ឃើញមានស្អីៗគេចាប់ចងនឹកឃើញអាណិតទៅ។

សេងគា ៖ ចឹងមីងជំបូងអត់មានចិត្តទេ ប៉ុន្តែក្រោយមកចិត្តហ្នឹងចាប់ផ្ដើមកើនទៅៗ ហើយក៏នៅជុំគ្នារហូតមក?

ដែនៈ ចាស! នៅជុំគ្នារហូតមកដល់ឃើញជាប់គុគនឹកឃើញគេចងហ្នឹងនឹកឃើញអាណិតរហូតមកទៅ។

សេងគា ៖ រហូតមកនៅរួមរស់ជាមួយគ្នាមានកូនមានចៅមានកូន៧នាក់ទៅ?

ដែនៈ មានកូន៧ ។

សេងគា ៖ បាទ! ចឹងអត់អីទេ អរគុណមីងច្រើន។

ដែនៈ ចាស ។

វិសាល ៖ មីងការគេរៀបការមីងហ្នឹង ខ្ញុំដឹងថាបង សេង គាសួរហើយមីងណាស់ ។

ដែនៈ ចាស ។

វិសាល ៖ ច្រើនគូរ ចឹងមែនទេមីង?

ដែនៈ ហ្នឹងហើយ ។

វិសាល ៖ ប៉ុន្មានគូរទៅ?

ដែនៈ ៥០គូរថ្ងៃជំបូងបីថ្ងៃហ្នឹង ។

វិសាល ៖ តាមដែលមីងអាចចាំបាន រហូតដល់ឥឡូវនេះមាននៅសេសសល់មានសេចក្ដីដូចជាមីងមាននៅប៉ុន្មានគូរដែរ?

ដែនៈ អរមិនបានដឹងព្រោះមិនបាននៅជិតផងអូន គេបានសុខគ្រប់គ្នាហ្នឹង ខ្លះណានេះបែកចឹងទៅណាស់ ។

វិសាល ៖ ខ្ញុំចង់និយាយថា បន្ទាប់ពីដួលរំលំរបបខ្មែរក្រហមមកពួកគាត់នៅជុំគ្នាច្រើនគូរទេ?

ដែនៈ មិនដឹងព្រោះមានតាមភូមិណា វាទូទាំងស្រុក ។

វិសាល ៖ ចឹងមិនបានដឹងទេ?

ដែនៈ មិនដឹងទេ ព្រោះការហ្នឹងមានតែមួយស្រុកយើងឬភូមិយើងអត់ទេ វាទូទាំងស្រុកហ្នឹងតែម្ដងគេរៀបជាគូរគ្នាចឹងទៅ ។

វិសាល ៖ ជាគំនិតរបស់មីង ចង់សួរជាយោបល់មីង មីងគិតថា ការរៀបការទាំងគូរចឹងមីងមានគិតថាជាការបង្ខំទេ?

ដែនៈ បន្ទុំមានពីណាស្រឡាញ់ពីណាផង បើគេត្រូវគ្នាគេស្រឡាញ់គេស្នើគ្នាទៅវិញទៅមក គេថាស្រឡាញ់នារីនេះ ហ្នឹងគេបានយកគ្នាទៅ អាខ្លះអត់មានស្រឡាញ់ទេចាប់ដាក់តែម្ដង ។

វិសាល ៖ ចឹងមានន័យថា វាមានពីរទើ១ គេអ្នកស្គាល់គ្នាអីចឹង គេមានចិត្តលើគ្នាគេស្នើដល់មេ ហើយមានមួយក្រុមទៀតនោះមិនដែលស្គាល់គ្នាសោះ ចាប់ឲ្យយកគ្នា?

ដែនៈ ខ្ញុំអត់មានស្គាល់គ្នាទេ គេចាប់ដាក់តែម្ដង ។

វិសាល ៖ ចឹងមីងគិតថាការចាប់បន្ទុំឲ្យរៀបការចឹងគួរចាត់ទុកជាបទឧក្រិដ្ឋមួយដែលខ្មែរក្រហមធ្វើដាក់ប្រជាពលរដ្ឋកាលសម័យនោះទេ ជាគំនិតផ្ទាល់?

ដែនៈ ចុះអាហ្នឹងបន្ទុំយើងហើយគំនិតវាមិននេះ ។

វិសាល ៖ ចឹងគិតថាជាបទឧក្រិដ្ឋមួយទេ?

ដែនៈ ហ្នឹងហើយ បើបន្ទុំយើងហើយ បើយើងមិនធ្វើតាមគេ គេសម្លាប់ចោល ។

វិសាល ៖ ភាគច្រើនហ្នឹងជាយោបល់ទេ អ្នកមីងណាស់?

ដែនៈ ចាស ។

វិសាល ៖ ភាគច្រើនពិតទេថា ខ្មែរយើងមានគំនិតថាការ ការតែម្ដងអីចឹងមិនចង់ការច្រើនដងអីចឹង ធ្វើឲ្យទំនាក់ទំនងប្ដីប្រពន្ធនៅចេះតែបន្តជាមួយគ្នារហូតអីចឹង អាចថាចឹងបានទេអ្នកមីង?

ដែនៈ ខ្ញុំមិនដឹងទេ ។

វិសាល ៖ អត់ដឹងទេ តែគ្រាន់តែអ្នកមីងអត់ស្គាល់គ្នា តែនៅជាមួយគ្នាចេះតែមានចិត្តទៅវិញទៅមករហូតដល់បច្ចុប្បន្នទៅ ។

ដែនៈ ចាស ។

វិសាល ៖ ចឹងអរគុណច្រើនមីង ។

ដែនៈ ចាស ។

**ចប់**